ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

លេខ៖ បព ៥៥/២០២៥ កបទ.សអ

សេចក្តីប្រកាសព័ត៌មាន

# លទ្ធផល នៃទស្សនកិច្ចរបស់ឯកឧត្តម ចូ ហ្យន់ (Cho Hyun) រដ្ឋមន្ត្រីការបរទេស នៃសាធារណរដ្ឋកូរ៉េ នៅព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី៩-១០ ខែវិច្ឆិកា ឆ្នាំ២០២៥

នៅថ្ងៃទី៩-១០ ខែវិច្ឆិកា ឆ្នាំ២០២៥ **ឯកឧត្តម ចូ ហ្យន់** (Cho Hyun) រដ្ឋមន្ត្រីការបរទេស នៃសាធារណរដ្ឋកូរ៉េ បានអញ្ជើញមកបំពេញទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងពង្រឹងបន្ថែមទៀតនូវទំនាក់ទំនងទ្វេភាគី និងភាពជាដៃគូយុទ្ធសាស្ត្ររវាងកម្ពុជា និងសាធារណរដ្ឋកូរ៉េ។ ក្នុងអំឡុងពេលទស្សនកិច្ច **ឯកឧត្តម ចូ ហ្យន់**បានចូលជួបសម្តែងការគួរសមចំពោះ**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ចូលរួមពិសាអាហារថ្ងៃត្រង់ការងាររៀបចំដោយ**ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងបានជួបពិភាក្សាជាមួយ**ឯកឧត្តម អភិសន្តិបណ្ឌិត ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ក្នុងឱកាសជំនួបសម្តែងការគួរសម នៅព្រឹកថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៥ **សម្តេចធិបតី** និង **ឯកឧត្តម ចូ ហ្យន់** បានវាយតម្លៃខ្ពស់ចំពោះវឌ្ឍនភាពលេចធ្លោ ដែលសម្រេចបានក្នុងការអភិវឌ្ឍទំនាក់ទំនងរវាងកម្ពុជា និងសាធារណរដ្ឋកូរ៉េ ក៏ដូចជាបានផ្លាស់ប្តូរយោបល់គ្នាអំពីវិធីសាស្ត្រក្នុងការពង្រីក និងធ្វើឱ្យស៊ីជម្រៅថែមទៀតនូវកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ រួមមានវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្មនិងការវិនិយោគ ការពារជាតិនិងសន្តិសុខ ឧស្សាហកម្ម ការបង្កើតតំបន់សេដ្ឋកិច្ចពិសេសសម្រាប់សហគ្រាសកូរ៉េ ទេសចរណ៍ និងការផ្លាស់ប្តូរប្រជាជននិងប្រជាជន។

នៅរសៀលថ្ងៃដដែល **ឯកឧត្តម ប្រាក់ សុខុន** បានរៀបចំពិធីអាហារថ្ងៃត្រង់ការងារជូន **ឯកឧត្តម ចូ ហ្យន់** ដែលក្នុងឱកាសនោះ ភាគីទាំងពីរបានបង្ហាញការពេញចិត្តចំពោះទំនាក់ទំនងដ៏កក់ក្តៅ និងរីកចម្រើនរវាងកម្ពុជា និងសាធារណរដ្ឋកូរ៉េ ក្នុងរយៈពេលជិតបីទសវត្សរ៍។ រដ្ឋមន្ត្រីការបរទេសទាំងពីរបានបញ្ជាក់ឡើងវិញពីការប្តេជ្ញាចិត្តរួមគ្នា ក្នុងការបន្តធ្វើឱ្យស៊ីជម្រៅកិច្ចសហប្រតិបត្តិការ

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីមែល: mfaic@mfaic.gov.kh

ដែលមានស្រាប់ និងស្វែងរកវិស័យនៃកិច្ចសហប្រតិបត្តិការថ្មី និងជាក់ស្តែងបន្ថែមទៀត ដើម្បីជំរុញបន្ថែមនូវភាពរឹងមាំ និងភាពធន់ នៃទំនាក់ទំនងកម្ពុជា-សាធារណរដ្ឋកូរ៉េ។

**ឯកឧត្តម ប្រាក់ សុខុន** ក៏បានជម្រាបជូន**ឯកឧត្តម ចូ ហ្យន់** អំពីវឌ្ឍនភាពថ្មីៗ ពាក់ព័ន្ធនឹងការអនុវត្តសេចក្តីថ្លែងការណ៍រួមគូឡាឡាំពួដែលបានចុះហត្ថលេខានៅថ្ងៃទី ២៦ ខែតុលា ឆ្នាំ២០២៥ ហើយបានសង្កត់ធ្ងន់អំពីការអនុវត្តដោយស្មោះត្រង់របស់កម្ពុជា ចំពោះការប្តេជ្ញានៅក្នុងសេចក្តីថ្លែងការណ៍នេះ។ ភាគីទាំងពីរក៏បានផ្លាស់ប្តូរទស្សនៈគ្នាលើបញ្ហាតំបន់ និងអន្តរជាតិ ដែលជាផលប្រយោជន៍រួមផងដែរ។

បន្ទាប់ពីពិធីអាហារថ្ងៃត្រង់ខាងលើ **ឯកឧត្តម ចូ ហ្យន់** បានជួបពិភាក្សាជាមួយ**ឯកឧត្តម អភិសន្តិបណ្ឌិត ស សុខា**។ ភាគីទាំងពីរក៏បានអញ្ជើញជាអធិបតីក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការបង្កើតក្រុមការងារចំពោះកិច្ចរួមកម្ពុជា-កូរ៉េ រវាងអគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជា និងទីភ្នាក់ងារនគរបាលជាតិកូរ៉េ៕

ថ្ងៃពុធ ៧រោច ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៥